ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

ថ្ងៃ ៥ កើត ១២ ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការគណនាប្រាក់ពន្ធនិងអាករប៉ាន់ស្មានសម្រាប់រថយន្តគ្មានពន្ធនិងអាករនាំចូលមានស្រាប់ក្នុងប្រទេស

អនុលោមតាមលិខិតរបស់រាជរដ្ឋាភិបាលលេខ ៤៨២ សជណ.ហធ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១ និងសេចក្តីជូនដំណឹងលេខ ១៩៨៣/២១ អគរ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អគរ) នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនសាធារណជន ពិសេសម្ចាស់រថយន្តគ្មានពន្ធនិងអាករនាំចូលដែលជ្រកក្រោមផ្លាកលេខផ្សេងៗ មេត្តាជ្រាបថា ដើម្បីបង្កភាពងាយស្រួលដល់ម្ចាស់រថយន្តអាចប៉ាន់ស្មានប្រាក់ពន្ធនិងអាករសម្រាប់រថយន្តគ្មានពន្ធនិងអាករនាំចូលមានស្រាប់ក្នុងប្រទេស អគរ សម្រេចដាក់ឱ្យប្រើប្រាស់មុខងារគណនាប្រាក់ពន្ធនិងអាករប៉ាន់ស្មាន សម្រាប់រថយន្តគ្មានពន្ធនិងអាករនាំចូលមានស្រាប់ក្នុងប្រទេស ដោយបានធ្វើបច្ចុប្បន្នភាពបន្ថែមមុខងារនេះក្នុងកម្មវិធីទូរសព្ទដែលសម្រាប់ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃបង្កាន់ដៃពន្ធយានយន្តនាំចូល ដែលមានឈ្មោះថា "Vehicle Document Verification" ពីប្រព័ន្ធ Google Play Store (ប្រតិបត្តិការ Android) និង Apple App Store (ប្រតិបត្តិការ iOS) ឬតាមរយៈគេហទំព័ររបស់ អគរ ដែលមានអាសយដ្ឋាន https://customs.gov.kh/local-vehicle-duty ។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

**សម្រាប់ទូរសព្ទ** Android **និង** iOS **សូមទាញយកដោយវាយពាក្យ** Vehicle Document Verification **នៅក្នុង** Apple App Store **ឬ** Google Play Store ។

**ឬតាមរយៈការស្កេនឃ្យូអាកូដ** (Qr Code)

https://goo.gl/V6AGHa

**ឬតាមរយៈគេហទំព័រអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

https://customs.gov.kh/local-vehicle-duty